**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...១៦៤....អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតសង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០២ នៃសង្កាត់កោះរ៉ុង គឺភូមិកោះតូច និងភូមិកោះរ៉ុងសន្លឹម។



www.pheakdeylaw.com

**មាត្រា ២.-**

សង្កាត់កោះរ៉ុងសន្លឹម មានភូមិចំនួន០២ គឺភូមិកោះតូច និងភូមិកោះរ៉ុងសន្លឹម។

ព្រំប្រទល់រដ្ឋបាលនៃសង្កាត់កោះរ៉ុងសន្លឹម ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៣.-**

ទីតាំងសាលាសង្កាត់កោះរ៉ុងសន្លឹម ស្ថិតនៅក្នុងភូមិកោះតូច ។

**មាត្រា ៤.-**

ការបង្កើតសង្កាត់កោះរ៉ុងសន្លឹម ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី៤ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់កោះរ៉ុង ត្រូវបន្តគ្រប់គ្រងភូមិចំនួន០២ គឺភូមិកោះតូច និងភូមិកោះរ៉ុងសន្លឹម រហូតដល់មានក្រុមប្រឹក្សាសង្កាត់កោះរ៉ុងសន្លឹមមកជំនួស។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសង្កាត់កោះរ៉ុងសន្លឹមត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សាខេត្តព្រះសីហនុ គណៈអភិបាលខេត្តព្រះសីហនុ ក្រុមប្រឹក្សាក្រុងព្រះសីហនុ គណៈអភិបាលក្រុងព្រះសីហនុ ក្រុមប្រឹក្សាសង្កាត់កោះរ៉ុង និងក្រុមប្រឹក្សាសង្កាត់កោះរ៉ុងសន្លឹម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារកាលប្បវត្តិ



www.pheakdeylaw.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ផែនទីព្រំប្រទល់រដ្ឋបាលសង្កាត់កោះរ៉ុងសន្លឹម
## ដោយបំបែកចេញពីសង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ




Projection,UTM,Zone 48N,Datum WGS 84

| Point_ID | X_Proj | Y_Proj |
|---|---|---|
| 1 | 309513.914 | 1180870.065 |
| 2 | 309959.747 | 1184763.318 |
| 3 | 310028.059 | 1184702.867 |
| 4 | 311543.800 | 1183145.835 |
| 5 | 312136.422 | 1182268.449 |
| 6 | 312183.995 | 1182129.720 |
| 7 | 312178.981 | 1182041.099 |
| 8 | 312183.115 | 1181975.871 |
| 9 | 312118.774 | 1181955.644 |
| 10 | 312128.292 | 1181762.517 |
| 11 | 312134.402 | 1181681.164 |
| 12 | 312146.619 | 1181569.583 |
| 13 | 312142.131 | 1181430.251 |
| 14 | 312158.658 | 1181293.580 |
| 15 | 312168.816 | 1181229.121 |
| 16 | 312162.129 | 1181187.677 |